# បន្ទុកសាធារណៈ

Alameda County
Social Services Agency

## វិធានថ្មីការពារគ្រួសារជនអន្តោប្រវេសន៍៖ តើអ្នកត្រូវដឹងអ្វីខ្លះ?



### តើនេះមានន័យអ្វីខ្លះ ចំពោះគ្រួសារខ្ញុំ?

- ប្រសិនបបើអ្នកមានលក្ខណៈសម្បត្តិទទួល អ្នកអាចជួយគ្រួសារអ្នកតាមរយៈជំនួយសាធារណៈ ដើម្បីធានាថា អ្នក កូន ប្តី/ប្រពន្ធ និង ឪពុក/ម្តាយរបស់អ្នក មានសុខភាពល្អ មានអាហារគ្រប់គ្រាន់ និងមានសន្តិសុខក្នុងលំនៅឋានរបស់អ្នក។
- វិធាននេះមិនផ្លាស់ប្តូរលក្ខណៈសម្បត្តិទទួលជំនួយ ឬសេវាកម្មសាធារណៈទេ។
- ព័ត៍មានដែលបានផ្តល់ ក្នុងការស្នើសុំអត្ថប្រយោជន៍សាធារណៈ គឺជាការសម្ងាត់ ហើយត្រូវបានប្រើសម្រាប់កំណត់លក្ខណៈសម្បត្តិតែប៉ុណ្ណោះ។ រដ្ឋាភិបាលរដ្ឋសហព័ន្ធមិនពិនិត្យប្រព័ន្ធអត្ថប្រយោជន៍សាធារណៈ ក្នុងគោលបំណងអនុវត្តច្បាប់អន្តោប្រវេសន៍ឡើយ។
- កុំឲ្យភាពភ័យខ្លាចអំពីឋានៈអន្តោប្រវេសន៍របស់អ្នក បញ្ឈប់អ្នកពីការស្វែងរកជំនួយ។ សេវាកម្មមានជូនបុគ្គល ដោយមិនគិតពីឋានៈឡើយ។

### វិធីប្រើប្រាស់សេវាកម្ម

ដាក់ពាក្យសុំអនឡាញនៅ **mybenefitscalwin.org** ឬ **www.coveredca.com**

ទូរស័ព្ទមកលេខ **510-272-3663** ដើម្បីដាក់ពាក្យសុំតាមទូរស័ព្ទ ឬស្នើសុំពាក្យសុំផ្ញើតាមប្រៃសណីយ៍ មកការិយាល័យសេវាកម្មសង្គមកិច្ចខោនធី Alameda ដើម្បីដាក់ពាក្យសុំដោយផ្ទាល់។

នៅខែកញ្ញា ឆ្នាំ2022 ក្រសួងសន្តិសុខជាតិសហរដ្ឋអាមេរិក (U.S. Department of Homeland Security (DHS)) បានដាក់ចេញនូវបទប្បញ្ញត្តិថ្មី ដែល**ផ្លាស់ប្តូរជាផ្លូវការ**នូវវិធានស្តីពីបន្ទុកសាធារណៈដែលមានលក្ខណៈព្យាបាត បង្កើតឡើងដោយរដ្ឋាភិបាលសេតវិមានមុន។ បទប្បញ្ញតិថ្មីធានាថា សហគមន៍អន្តោប្រវេសន៍មានសិទ្ធិ៖

ដាក់ពាក្យស្នើសុំ និងទទួលបានអត្ថប្រយោជន៍សាធារណៈភាគច្រើន ដែលខ្លួនមានលក្ខណៈសម្បត្តិទទួល **ដោយមិន**ប៉ះពាល់លើឋានៈអន្តោប្រវេសន៍បច្ចុប្បន្ន ឬអនាគតរបស់ខ្លួនឡើយ ដែលរាប់បញ្ចូល៖

- លទ្ធភាពទទួលបានការថែទាំសុខភាព
  - កម្មវិធី Medi-Cal សម្រាប់កុមារ មនុស្សពេញវ័យ និងចាស់ជរា
  - កម្មវិធី Covered California
  - ថ្នាំវ៉ាក់សាំង ការធ្វើតេស្ត និងការព្យាបាលជំងឺកូវីដ
  - ការថែទាំស្តារសម្បទាឡើងវិញក្នុងរយៈពេលខ្លី
  - សេវាកម្មនៅផ្ទះ និងក្នុងសហគមន៍
- ជំនួយអាហារ
  - កម្មវិធី CalFresh
  - កម្មវិធីអាហារូបត្ថម្ភពិសេសសម្រាប់ស្ត្រី ទារ និងកុមារ (Special Supplemental Nutrition Program for Women, Infants & Children (WIC))
  - អាហារនៅសាលារៀន
- ជំនួយលំនៅឋាន
  - ជំនួយថ្លៃជួល Section 8
  - លំនៅឋានសាធារណៈ
- ជំនួយការងារ
  - ភាពឥតការងារធ្វើ
  - ពិការភាព
  - សំណងសម្រាប់កម្មករ
  - មជ្ឈមណ្ឌលការងារ WIOA
  - សោធនិវត្តន៍របស់រដ្ឋ និងរដ្ឋសហព័ន្ធ
  - EITC ឬឥណទានពន្ធកុមារ
- អត្ថប្រយោជន៍មិនមែនសាច់ប្រាក់របស់រដ្ឋសហព័ន្ធ រដ្ឋ និងរដ្ឋបាលមូលដ្ឋាន
  - Season of Sharing (SOS)
  - ជំនួយវិបត្តិជំងឺរាតត្បាត
  - ជំនួយអតីតយុទ្ធជន
  - កម្មវិធីជំនួយថាមពលសម្រាប់គ្រួសារចំណូលទាប (Low Income Home Energy Assistance Program (LIHEAP))
  - កម្មវិធីភ្ជាប់ប្រព័ន្ធក្នុងតម្លៃសមរម្យ (Affordable Connectivity Program)

# បន្ទុកសាធារណៈ

Alameda County Social Services Agency

## វិធានថ្មីការពារគ្រួសារជនអន្តោប្រវេសន៍

បទប្បញ្ញត្តិថ្មីរបស់ DHS ចែងបំភ្លឺថា ការវាយតម្លៃអំពីបន្ទុកសាធារណៈ កើតឡើងតែនៅពេលដែលជនណាម្នាក់ស្នើសុំសិទ្ធិរស់នៅអចិន្ត្រៃយ៍ (LPR ឬ “ហ្គ្រីនកាត”) ឬចូលក្នុងទឹកដីសហរដ្ឋអាមេរិក។ ជនអន្តោប្រវេសន៍មួយចំនួន ត្រូវបានលើកលែងពីតេស្តបន្ទុកសាធារណៈ ដែលរួមបញ្ចូល៖

- ពលរដ្ឋអាមេរិក (ឬអ្នកសុំសញ្ជាតិ)
- អ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ (LPR)
- ជនភៀសខ្លួន អ្នកសុំសិទ្ធិជ្រកកោន ឬ TPS (ឬអ្នកស្នើសុំ)
- ជនជាតិអាហ្វហ្គានីស្ថាន ឬអ៊ីរ៉ាក់ដែលកាន់ទិដ្ឋាការអន្តោប្រវេសន៍ពិសេស
- អនីតិជនអន្តោប្រវេសន៍ពិសេស ឬអ្នកស្នើសុំផ្អែកលើច្បាប់ VAWA
- អ្នកកាន់ទិដ្ឋាការ U ឬ V (ឬអ្នកសុំទិដ្ឋាការ)



តេស្តបន្ទុកសាធារណៈ នឹង**មិន**ពិចារណាលើពាក្យសុំរបស់អ្នក ឬការទទួលបាននូវអត្ថប្រយោជន៍សាធារណៈតាងនាមឲ្យកូនរបស់អ្នក ឬសមាជិកមានលក្ខណៈសម្បត្តិផ្សេងទៀតឡើយ។

ប្រសិនបើអ្នកស្នើសុំ LPR ឬសិទ្ធិចូលក្នុងទឹកដីសហរដ្ឋអាមេរិក **កម្មវិធី** ដែលត្រូវបានពិចារណាក្នុងតេស្តបន្ទុកសាធារណៈ រួមមាន៖

- កម្មវិធីជំនួយសាច់ប្រាក់ ដូចជា កម្មវិធី CalWORKs, កម្មវិធី General Assistance (GA), និងកម្មវិធី Supplemental Security Income (SSI)
- ការថែទាំរយៈពេលវែងក្នុងស្ថាប័ន ដែលបង់ដោយកម្មវិធី Medi-Cal

បើទោះបីជាអ្នកប្រើអត្ថប្រយោជន៍ទាំងនេះក៏ដោយ ក៏ប៉ុន្តែ កត្តាផ្សេងទៀត ដូចជា សេចក្តីបញ្ជាក់ពីការឧបត្ថម្ភ ការអប់រំ និងជំនាញរបស់អ្នក ប្រាក់ចំណូល និងរយៈពេលទទួលអត្ថប្រយោជន៍ និងរយៈពេលថ្មីៗ នឹងត្រូវបានពិចារណាក្នុងការកំណត់ពីបន្ទុកសាធារណៈ។

ដើម្បីស្វែងរកព័ត៌មានបន្ថែមអំពីបន្ទុកសាធារណៈ សូមចូលទៅ៖

- រក្សាអត្ថប្រយោជន៍របស់អ្នក
- ការពារគ្រួសារជនអន្តោប្រវេសន៍
- មជ្ឈមណ្ឌលច្បាប់អន្តោប្រវេសន៍ជាតិ
- ក្រសួងសេវាកម្មសង្គមកិច្ចរដ្ឋ California
- ប្រភពធនធានបន្ថែមពីបន្ទុកសាធារណៈរបស់ USCIS

### កំពុងស្វែងការណែនាំជាលក្ខណៈបុគ្គលឬ?

ទីភ្នាក់ងារសេវាកម្មសង្គមកិច្ចលើកទឹកចិត្តបុគ្គល និងគ្រួសារ ឲ្យស្នើសុំយោបល់ពីអ្នកផ្តល់សេវាកម្មអន្តោប្រវេសន៍មានកេរ្តិ៍ឈ្មោះ និងមិនស្វែងរកប្រាក់ចំណេញ។ បុគ្គលិក SSA មិនអាចផ្តល់ការណែនាំផ្លូវច្បាប់បានទេ។ ដើម្បីទទួលបានការណែនាំ អំពីស្ថានភាពនីមួយៗរបស់អ្នក សូមទាក់ទង៖

- Asian Pacific Islander Legal Outreach
  (510) 251-2846
- Bay Area Legal Aid
  (800) 551-5554 or (510) 250-5270
- Catholic Charities of the East Bay
  (510) 768-3100
- Centro Legal De La Raza
  (510) 437-1554
- East Bay Community Law Center
  (510) 548-4040

*អត្ថប្រយោជន៍ដែលរាយបញ្ជីនៅទំព័រទី 1 និងឋានៈអន្តោប្រវេសន៍ដែលត្រូវបានលើកឡើងនៅទំព័រទី 2 មិនមែនជាបញ្ជីពេញលេញទេ សូមទាក់ទងសេវាកម្មមានឈ្មោះខាងលើ ដើម្បីទទួលបានយោបល់អំពីសំណុំរឿងរបស់អ្នក។